ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Apr-2011, 09:11
CMS/CFO: Phok Chanthan



[ERN 00000088]

# ទង់កិត្យានុភាព សមត្ថភាព និងកិត្តិយសរបស់ជាតិ របស់ប្រជាជនកម្ពុជា របស់រណសិរ្សរួបរួមជាតិកម្ពុជា (រ.រ.ជ.ក.) និងរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា អណ្តែតខ្ពស់ត្រដែតលើឆាកអន្តរជាតិ

<u>ទីភ្នាក់ងារព័ត៌មានកម្ពុជា ចេញផ្សាយថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៧៤</u>

គណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលដឹកនាំដោយលោក ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការកងទ័ពប្រជាជនរំដោះជាតិកម្ពុជា និងលោក អៀង សារី ទីប្រឹក្សាពិសេសនៃទីស្តីការគណៈរដ្ឋមន្ត្រីរងរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា កំពុងបំពេញទស្សនកិច្ចមិត្តភាពជាផ្លូវការនៅប្រទេសជាមិត្ត និងជាបងប្អូនមួយចំនួន ដូចជា សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម សាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ។ ប្រជាជន រដ្ឋាភិបាល និងអង្គការមហាជនជាច្រើននៃប្រទេសទាំងនេះ បានទទួលគណៈប្រតិភូកម្ពុជាយ៉ាងគគ្រឹកគគ្រេង មហោឡារិក និងស្និទ្ធស្នាល។ សាមគ្គីប្រយុទ្ធ និងមិត្តភាពជាបងប្អូន ក្នុងភាពស្មើគ្នារវាងជាតិប្រជាជនកម្ពុជា និងប្រជាជននៃប្រទេសជាបងប្អូនជាមិត្ត បានលើកកំពស់គ្នា និងសាមគ្គីគ្នាបានមួយកម្រិតខ្ពស់។ ភ្នាក់ងារសារព័ត៌មានបស្ចិមប្រទេស ដែលគាំទ្រពួកចក្រពត្តិអាមេរិកជាញឹកញាប់ និងពួកអាក្បត់ក្រុងភ្នំពេញ កំពុងតែតាមដំណឹងអំពីដំណើរទស្សនកិច្ចនេះដោយយកចិត្តទុកដាក់ផងដែរ និងបានផ្សព្វផ្សាយព័ត៌មានស្តីពីព្រឹត្តិការណ៍ដ៏សំខាន់នេះ នៅគ្រប់ទិសទីទូទាំងពិភពលោក។ ទស្សនាវដ្តីវិទ្យុផ្សាយសម្លេង និងទូរទស្សន៍នានា បានធ្វើរបាយការណ៍ បទអត្ថាធិប្បាយយ៉ាងគគ្រឹកគគ្រេង ពីពាក្យសម្តី និងសន្ទរកថារបស់លោកឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ប្រធានគណៈប្រតិភូ ពីការទទួលស្វាគមន៍រូបលោកនៅតាមរដ្ឋធានីនៃប្រទេសនីមួយៗ ពីបដិសណ្ឋារកិច្ច និងដំណើរទស្សនកិច្ចនៅតាមរោងចក្រ និងកន្លែងផ្សេងៗទៀត ព្រមទាំងពីការប្រារព្ធមិទ្ទីញមហាជន។ល។

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

បច្ចុប្បន្ននេះ កិត្តិយសរបស់ជាតិ និងប្រជាជនកម្ពុជា កិត្តិសព្ទ សមត្ថភាពរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានឡើងមកដល់កម្រិតយ៉ាងខ្ពស់។ តើវាបណ្ដាលមកពីមូលហេតុអ្វី?

ដំណើរទស្សនកិច្ចទាំងនេះបានទទួលនូវភាពគគ្រឹកគគ្រេង មហោឡារិក និងវិសាលភាពបែបនេះ ចំពោះមតិអន្តរជាតិ មតិមិត្ត ក៏ដូចជាពួកមិនមែនជាមិត្ត ពីព្រោះគណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលដឹកនាំដោយលោក ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី និងលោក អៀង សារី ទីប្រឹក្សាពិសេសនៃ ទីស្ដីការគណៈរដ្ឋមន្ត្រីរងរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា តំណាងឱ្យជាតិ ប្រជាជនកម្ពុជា និងចលនាតស៊ូប្រឆាំងនឹងពួកចក្រពត្តិអាមេរិក ដើម្បីរំដោះជាតិនៅលើសមរភូមិដ៏ក្ដៅគគុកជាងគេបំផុតនៅលើពិភពលោកនាបច្ចុប្បន្នកាលនេះ ដែលជាចលនាតស៊ូឯករាជ្យម្ចាស់ការសុទ្ធសាធ ដោយមិនពឹងផ្អែកទៅលើប្រទេសបរទេសណាមួយឡើយ និងកាន់ក្ដាប់ជោគវាសនាប្រទេសរបស់ខ្លួន និងប្រជាជនរបស់ខ្លួន។ រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គឺជាអ្នកតំណាងពិតប្រាកដនៃចលនាតស៊ូរំដោះប្រទេសតូចតាចរងគ្រោះនៃអំពើឈ្លានពានដ៏សាហាវព្រៃផ្សៃបំផុត និងដែលកំពុងតែឈ្នះពួកចក្រពត្តិឈ្លានពានអាមេរិក ដែលជាមេខ្លោងរបស់ពួកចក្រពត្តិអន្តរជាតិទាំងអស់។

រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាខុសគ្នាស្រឡះដូចមេឃនឹងដី ពីបន "សាធារណរដ្ឋ"ប្រឆាំងជាតិឯង នៃក្រុងភ្នំពេញ ដែលគ្មានទាំងប្រជាជន ទាំងទឹកដី ទាំងស្រូវ ជាពួកមហាផាសុីសមហាពុករលួយ ពួកបរិវារដ៏ស្មោះស្ម័គ្ររបស់ពួកចក្រពត្តិអាមេរិក។ ពួកអាក្បត់ក្រុងភ្នំពេញទៅត្រង់ណា មហាជនមើលងាយ ស្អប់ខ្ពើមពួកវា ហើយចង់ក្អួតត្រង់កន្លែងនោះ

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

[ERN 00000089]

ដោយសារពួកវាជាក្រុមចោរមួយក្ដាប់តូចប្រឆាំងជាតិឯង ដែលរស់ទាំងត្រដាបត្រដួស ដោយសារមានការផ្គត់ផ្គង់ពីចក្រពត្តិអាមេរិក និងមួយថ្ងៃៗគិតតែពីលុតជង្គង់សំពះសុំទានចៅហ្វាយធំតូចរបស់ខ្លួន។ លើសពេលណាៗទាំងអស់ មហាជនក្នុងប្រទេសក៏ដូចជានៅបរទេស មើលឃើញយ៉ាងច្បាស់នូវចរិតឯករាជ ម្ចាស់ការមិនពឹងផ្អែកលើបរទេស ភាពរុងរឿង កិត្តិយស និងកិត្តិសព្ទល្បីរន្ទឺ របស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ព្រមទាំងមើលឃើញផងដែរពីចរិតផ្ទុយគ្នាទាំងស្រុងដូចយប់នឹងថ្ងៃពីបនក្បត់ក្រុងភ្នំពេញ ដែលស្មោះស្ម័គ្រធ្វើជាបរិវារដ៏ថោកទាបបំផុតរបស់ពួកចក្រពត្តិអាមេរិក។ សង្គ្រាមចិត្តសាស្ត្រអសីលធម៌ និងថោកទាបបង្កដោយ CIA ក្នុងបំណងមួលបង្កាច់ និងលេបត្របាក់ចលនាតស៊ូរបស់ជាតិ និងប្រជាជនកម្ពុជា ត្រូវបានបំបែកផ្ទួនៗ ហើយឥឡូវនេះកំពុងតែដួលរលំកាន់តែខ្លាំងជាងមុន។

ជាតិ ប្រជាជន យុទ្ធជន យុទ្ធនារី និងកម្មាភិបាលកម្ពុជា មានមោទនភាពយ៉ាងខ្លាំងចំពោះជ័យជំនះនេះ។ ពិតប្រាកដណាស់ ជ័យជំនះនេះបានមកពីការតស៊ូដ៏ស្វិតស្វាញ និងវីរភាពបដិវត្តដ៏ថ្លៃថ្លារបស់ប្រជាជន និងកងទ័ពប្រជាជនរំដោះជាតិកម្ពុជា ដែលដើរតាមមាគ៌ាវាយសម្រុកជាប់ជានិច្ច ដាច់ខាតបំផុត ដោយមិនទទួលយកការសម្រុះសម្រួល និងដោយគ្មានស្មារតីដកថយឡើយ នៅក្រោមទង់ដ៏រុងរឿងរបស់រណសិរ្សរួបរួមជាតិកម្ពុជា។ នៅថ្ងៃខាងមុខ កងទ័ពប្រជាជនរំដោះជាតិកម្ពុជា នឹងបើកការវាយប្រហារឲ្យកាន់តែខ្លាំងក្លាជាងនេះថែមទៀត ដើម្បីជ្រោងឲ្យកាន់តែខ្ពស់នូវទង់កិត្តិសព្ទ ទង់សមត្ថភាព ទង់កិត្តិយសជាតិ ទង់ប្រជាជន ទង់របស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា រហូតដល់ដណ្តើមបានជោគជ័យទាំងស្រុង និងជាស្ថាពរ លើពួកចក្រពត្តិអាមេរិក ពួកបរិវាររបស់វា និងពួកអាក្បត់ ឡុង បូរ៉េត និង សូស្តែន ហ្វែរណង់ដែស (Sosthène FERNANDEZ)។

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

# គណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ចាកចេញពីទីក្រុងប៉េកាំង ឆ្ពោះទៅកាន់ទីក្រុងព្យុងយ៉ាង

<u>ទីភ្នាក់ងារព័ត៌មានកម្ពុជា ចេញផ្សាយថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៤</u>

គណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានលោក ខៀវ សំផន សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមនៃរណសិរ្សរួបរួមជាតិកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងអគ្គមេបញ្ជាការនៃកងទ័ពប្រជាជនរំដោះជាតិកម្ពុជា ជាប្រធាន និងលោក អៀង សារី ទីប្រឹក្សាពិសេសនៃទីស្តីការរងនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានចាកចេញពីទីក្រុងប៉េកាំង កាលពីថ្ងៃទី ៥ ខែមេសា តាមជើងយន្តហោះពិសេស ដើម្បីទៅធ្វើទស្សនកិច្ចនៅប្រទេសកូរ៉េ ទៅតាមការអញ្ជើញរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាជាមានិតប្រជាធិបតេយ្យកូរ៉េ។

នៅពេលចេញដំណើរ គណៈប្រតិភូត្រូវបានទទួលអបអរសាទរនៅព្រលានយន្តហោះ ដោយអ្នកដឹកនាំចិន និងប្រធានការិយាល័យពាក់ព័ន្ធ ដូចជាលោក យេ គានយីង (Ye Kien-Ying) លោក វូ ទេស (Wou Teh) លោក កេង ពាវ (Keng Piao) លោក លី គាង (Li Kiang) លោក ចាង ចាយ ចៀន (Tchang Tsai-Tsien) លោក ហាន នៀនឡុង (Han Nien-Long) និង លោក ចេង គៀន (Cheng Kien) ព្រមទាំងឯកអគ្គរដ្ឋទូតចិនប្រចាំនៅប្រទេសកម្ពុជា លោក កាំង ម៉ៅចាវ (Kang Mao-Tchao)។

[ERN 00000090]

សម្តេច ប៉ែន នុត នាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា លោក សារិន ឆាក លោក ចាន់ យូរ៉ាន់ លោក ជួន មុំ ឧត្តមសេនីយ៍ ដួង សំអុល លោក ជា សាន លោក គាត ឈន់ លោក ជួន ប្រសិទ្ធ និង លោក រ៉ាន់ ពីនី ព្រមទាំងឯកអគ្គរាជទូត តូច ខាំឌឿន ក៏មាននៅក្នុងឱកាសនេះផងដែរ។

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

លោក ហ៊ីយុន យុនកឹក ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េប្រចាំនៅប្រទេសចិន និងភរិយា ក៏មានវត្តមាននៅទីនោះដែរ។

## គណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មកដល់ទីក្រុងព្យុងយ៉ាង

<u>ទីភ្នាក់ងារព័ត៌មានកម្ពុជា ចេញផ្សាយថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៧៤</u>

គណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាបានមកដល់ទីក្រុងព្យុងយ៉ាង នៅថ្ងៃទី ៥ ខែ មេសា តាមជើងយន្តហោះពិសេស ដើម្បីបំពេញទស្សនកិច្ចមិត្តភាព នៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ទៅតាមការអញ្ជើញរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ។

គណៈប្រតិភូត្រូវបានដឹកនាំដោយលោក ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងអគ្គមេបញ្ជាការ នៃកងទ័ពប្រជាជនរំដោះជាតិកម្ពុជា និងលោកអនុប្រធានគណៈប្រតិភូ អៀង សារី ទីប្រឹក្សាពិសេសនៃទីស្តីការរង នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

សមជិកគណៈប្រតិភូរួមមាន លោកស្រី អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងអប់រំប្រជាជន និងយុវជន លោកទីវ អុល អនុរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការ និងលោក អាង គីមឃាន់ ឯកអគ្គរាជទូតនៃរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ។

ភ្ញៀវកម្ពុជាត្រូវបានទទួលអបអរសាទរ នៅព្រលានយន្តហោះដោយលោក Tchoe Yung Keun សមាជិកគណៈកម្មធិកានយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សពលករកូរ៉េ និងជាអនុប្រធានាធិបតី

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងលោក O Jin U លោក Pak Sung Chul លោក Ho Dam រួមទាំងឥស្សរជនផ្សេងៗទៀត។

មានវត្តមាននៅក្នុងឱកាសនេះផងដែរ រួមមាន លោក Li Yun-Tchouan ឯកអគ្គរដ្ឋទូតចិនប្រចាំនៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងបេសកជនការទូតមកពីប្រទេសផ្សេងៗដែលត្រូវបានតែងតាំងនៅកូរ៉េ។

នៅពេលភ្ញៀវកម្ពុជាបានចុះពីលើយន្តហោះ លោកអនុប្រធានាធិបតី Tchoe Yung Keun និងអ្នកដឹកនាំបក្ស រដ្ឋាភិបាលកូរ៉េ បានធ្វើដំណើរទៅដើម្បីចាប់ដៃ និងអោបគ្នាទៅវិញទៅមកយ៉ាងរាក់ទាក់។ កុមារកូរ៉េបានជូនបាច់ផ្កាដល់ពួកគាត់។

ពិធីបដិណ្ឋារកិច្ចដ៏ធំមួយបានប្រព្រឹត្តទៅនៅព្រលានយន្តហោះ។ ក្រុមភ្លេងត្រែបានលេងភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ។ ឧបនាយករដ្ឋមន្ត្រី ខៀវ សំផន និងទីប្រឹក្សាពិសេស អៀង សារី អមដោយអ្នកដឹកនាំកូរ៉េ បានដើរត្រួតពលកិត្តិយសរបស់កងទ័ពប្រជាជនកូរ៉េ។

នៅពេលដែលភ្ញៀវកម្ពុជាបានទៅជួបអ្នកមកទទួល ពួកគេបានគ្រវីទង់ជាតិប្រទេសទាំងពីរ និងស្រែកអបអរសាទរ សម្តែងការស្វាគមដ៏កក់ក្តៅដល់និរសារនៃប្រជាជនកម្ពុជា ដែលមកពីសមរភូមិមុខប្រឆាំងនឹងពួកចក្រពត្តិ។

[ERN 00000091]

នៅឯទីក្រុង ភ្ញៀវកម្ពុជាត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅដោយប្រជាជនរាប់ម៉ឺននាក់ ដែលប្រមូលផ្តុំគ្នានៅតាមផ្លូវ។

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

# ប្រធានាធិបតី គីម អ៊ីលស៊ុង ទទួលគណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

<u>ទីភ្នាក់ងារព័ត៌មានកម្ពុជា ចេញផ្សាយថ្ងៃទី ៧ ខែ មេសា ឆ្នាំ ១៩៧៤</u>

លោកសេនាប្រមុខ គីម អ៊ីលស៊ុង ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតប្រជាធិប តេយ្យកូរ៉េ បាន ទទួលគណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅថ្ងៃទី ៥ ខែ មេសា ក្នុងឱកាសទស្សនកិច្ចមិត្តភាពផ្លូវការ នៅប្រទេសកូរ៉េ។

មានវត្តមាននៅក្នុងឱកាសនោះរួមមាន លោក ខៀវ សំផន សមាជិកការិយាល័យនយោបាយមជ្ឈិម បក្សរបស់រ.រ.ជ.ក. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងអគ្គមេបញ្ជាការ នៃកងទ័ពប្រជាជនរំដោះជាតិកម្ពុជា ជាប្រធានគណៈប្រតិភូ និង លោក អៀង សារី ទីប្រឹក្សាពិសេសនៃទីស្តីការរងនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាអនុប្រធានគណៈប្រតិភូ រួម ទាំងសមាជិកគណៈប្រតិភូ ដូចជា អ្នកស្រី អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងអប់រំប្រជាជន និងយុវជន លោក ទីវ អុល អនុរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា លោក អាង គីមឃាន់ ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យ កូរ៉េ។

នៅទីនោះ គេសង្កេតឃើញផងដែរវត្តមានរបស់ លោក O Jin U លោក Pak Sung Chul លោក Ho Dam លោក Kim Yong Nam លោក Li Chong Il និងឥស្សរជនកូរ៉េផ្សេងៗទៀត។

លោកប្រធានាធិបតី គីម អ៊ីលស៊ុង បានគូសបញ្ជាក់ថាការតស៊ូដ៏អង់អាចក្លាហានរបស់ប្រជាជនកម្ពុជា ធ្វើឱ្យប្រជាជនទូទាំងពិភពលោក ប្រជាជននៃទ្វីបអាស៊ី និងប្រជាជនកូរ៉េចង់យកគំរូតាម។ គាត់បាន

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

ចង្អុលបង្ហាញថា “ការតស៊ូរបស់ប្រជាជនកម្ពុជាបង្ហាញឲ្យឃើញថា ប្រទេសតូចមួយអាចយកជ័យជំនះ ក្នុងការតស៊ូប្រឆាំងនឹងមហាអំណាចចក្រពត្តិបាន”។

ជួសមុខឲ្យប្រជាជនកូរ៉េ លោក គីម អ៊ីលស៊ុង បានអបអរសាទរយ៉ាងកក់ក្តៅចំពោះជ័យជំនះដ៏ត្រចះត្រចង់ដែលវីរប្រជាជនកម្ពុជាទទួលបាន ក្នុងការតស៊ូប្រឆាំងនឹងការឈ្លានពានរបស់សហរដ្ឋ អាមេរិក ដើម្បីស្រោចស្រង់ជាតិ ហើយគាត់បានជូនពរឲ្យប្រជាជនកម្ពុជាទទួលជ័យជំនះកាន់តែល្បីរន្ទឺជាងនេះទៅទៀត។ គាត់បានប្រកាសថាប្រជាជនកូរ៉េចាត់ទុកថាជំនួយដែលគេផ្តល់ជូនដល់ប្រជាជនកម្ពុជា ក្នុងការតស៊ូដ៏ត្រឹមត្រូវ ជាកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន។

ចំណែកលោក ខៀវ សំផន វិញ លោកបានពាំនាំការអបអរសាទររបស់ប្រជាជន យុទ្ធជនកម្ពុជា ចំពោះលោកប្រធាធិបតី គីម អ៊ីលស៊ុង ប្រជាជនកូរ៉េ និងបក្សពលករកូរ៉េ។ លោកបានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រជូនលោកប្រធាធិបតី គីម អ៊ីលស៊ុង និងប្រជាជនកូរ៉េ ចំពោះជំនួយយ៉ាងសកម្មរបស់ពួកគេ ដល់ការតស៊ូរបស់ប្រជាជនកម្ពុជា។

គណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានជូនដល់ប្រធានាធិបតី គីម អ៊ីលស៊ុង នូវអំណោយអនុស្សាវរីយផលិតឡើងដោយប្រជាជន និងយុទ្ធជននៃកងទ័ពប្រជាជនរំដោះជាតិកម្ពុជា។

ការសំណេះសំណាលបានប្រព្រឹត្តទៅ ក្នុងបរិយាកាសមិត្តភាព ភាតរភាពប្រយុទ្ធ។

[ERN 00000092]

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

# ពិធីលៀងសាយភោជននៅទីក្រុងព្យុងយ៉ាង ជាកិត្តិយសដល់គណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

<u>ទីភ្នាក់ងារព័ត៌មានកម្ពុជា ចេញផ្សាយថ្ងៃទី ៧ ខែ មេសា ឆ្នាំ ១៩៧៤</u>

នៅថ្ងៃទី ៥ ខែ មេសា នៅក្នុងសាសវដ្ដសភា នាទីក្រុង Mansudae គណៈកម្មាធិការប្រជាជនមជ្ឈិម និងក្រុមប្រឹក្សាអភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ បានរៀបចំពិធីលៀងសាយភោជនជាកិត្តិយសដល់គណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលកំពុងបំពេញទស្សនកិច្ចនៅប្រទេសកូរ៉េ។

លោកសេនាប្រមុខ គីម អ៊ីលស៊ុង ប្រធាធិបតីនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ មានវត្តមានក្នុងពិធីលៀងសាយភោជននេះដែរ។ ខាងភាគីកម្ពុជាដែលមានវត្តមាននៅក្នុងពិធី មាន លោក ខៀវ សំផន សមាជិក ការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សនៃរណសិរ្សរួបរួមជាតិកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងអគ្គមេបញ្ជាការនៃកងទ័ពប្រជាជនរំដោះជាតិកម្ពុជា ជាប្រធានគណៈប្រតិភូ អៀង សារី ទីប្រឹក្សាពិសេសនៃទីស្ដីការរងនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាអនុប្រធានគណៈប្រតិភូ និងសមាជិកគណៈប្រតិភូផ្សេងៗទៀត។ ខាងភាគីកូរ៉េ មានលោក Tchoe Yong Keun អនុប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងលោក O Jin U លោក Pak Sung Chul លោក Ho Dam លោក Kim Yong Nam លោក Tchoe Jai U ជារដ្ឋមន្ត្រីនៃទីស្ដីការក្រុមប្រឹក្សាភិបាល អ្នកទទួលខុសត្រូវអង្គការមហាជន ជាឧត្តមសេនីយនៃកងទ័ពប្រជាជន អ្នកទទួលខុសត្រូវវិស័យវិទ្យាសាស្ត្រ អប់រំ វប្បធម៌ សិល្បៈនិងសារព័ត៌មាននៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ។

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

បុគ្គលិកស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសកូរ៉េ អ្នកការទូតមកពីប្រទេសនានាដែលត្រូវបានតែងតាំងនៅប្រទេសកូរ៉េ និងនិស្សិតខ្មែរកំពុងសិក្សានៅកូរ៉េ ក៏ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងពិធីលៀងសាយភោជននេះដែរ។

នៅពេលដែលលោកសេនាប្រមុខ គីម អ៊ីលស៊ុង លោកឧបនាយករដ្ឋមន្ត្រី ខៀវ សំផន និងលោកទីប្រឹក្សាពិសេស អៀង សារី ព្រមទាំងឥស្សរជនផ្សេងៗទៀត ដើរចូលក្នុងសាលពិធីលៀងសាយភោជន ពួកគាត់ត្រូវបានទទួលស្វាគមន៍ ក្រោមសម្លេងតន្ត្រី និងស្នូរទះដៃអបអរសាទរយ៉ាងយូរ។

ភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា និងភ្លេងជាតិកូរ៉េ បានប្រគំឡើង។

លោក O Jin U និង លោក ខៀវ សំផន បានធ្វើសង្កថា ក្នុងពិធីលៀងសាយភោជននេះ។

អ្នកចូលរួមបានលើកកែវ ដើម្បីជូនពរសុខភាពល្អ និងអាយុយឺនយូរដល់លោកប្រធានាធិបតី គីម អ៊ីលស៊ុង សម្តេចប្រមុខរដ្ឋ នរោត្តម សីហនុ សម្តេចនាយករដ្ឋមន្ត្រី ប៉ែន នុត ឧបនាយករដ្ឋមន្ត្រី ខៀវ សំផន និងទីប្រឹក្សាពិសេស អៀង សារី។

ពិធីលៀងសាយភោជនបានប្រព្រឹត្តទៅ ក្នុងបរិយាកាសសាមគ្គីភាពប្រយុទ្ធ និងមិត្តភាពជាបងប្អូន និងត្រូវបានបញ្ចប់ជាមួយការសម្តែងសិល្បៈដោយក្រុមសិល្បៈ Mansudae។

[ERN00000093]

## កងទ័ពរបស់ពួកអាក្សត់ក្រុងភ្នំពេញកំពុងតែបាក់ស្មារតី និងជាប់ក្នុងស្ថានភាពការពារខ្លួនលើរាល់សមរភូមិ ក្នុងខណៈដែលកងទ័ពប្រជាជន

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

# រំដោះជាតិកម្ពុជាកំពុងតែបន្តការផ្ដួចផ្ដើមវាយប្រហារខ្មាំងឥតស្រាកស្រាន

<u>ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ចេញផ្សាយថ្ងៃទី ៤ ខែ មេសា ឆ្នាំ ១៩៧៤</u>

ព្រឹត្តិការណ៍ដែលបានកើតឡើងលើទីលានប្រយុទ្ធ ក្នុងរដូវប្រាំងនេះ បង្ហាញយ៉ាងច្បាស់ថាប្រជាជន និងកងទ័ពប្រជាជនរំដោះជាតិកម្ពុជាអាចរុញច្រានខ្មាំងតាមចិត្ត ទៅកន្លែងណា និងពេលណាក៏បាន ដើម្បីយកជ័យជំនះលើវា និងធ្វើឲ្យវាទទួលរងការបាត់បង់ដ៏ធ្ងន់ធ្ងររាល់លើក។

កងទ័ពប្រជាជនរំដោះជាតិកម្ពុជាធ្វើការវាយប្រហារជាប់រហូត ក្នុងខណៈដែលខ្មាំងរត់តាមស្ថានភាពជានិច្ច ដើម្បីព្យាយាមយកប្រៀបលើយើង ប៉ុន្តែវាមិនអាចទៅរួចទេ។ ប្រជាជនកម្ពុជា និងអ្នកសង្កេត-ការណ៍បរទេសដឹងច្បាស់ណាស់អំពីរឿងនេះ។ នៅក្នុងសង្គ្រាមចិត្តសាស្ត្រនេះ ទោះបីជាខំប្រឹងប្រែងដោយឆ្គួតលីលា និងចោកទាបយ៉ាងណាក៏ដោយ ក៏ពួកអាក្បត់ក្រុងភ្នំពេញមិនអាចស្រោចស្រង់បរាជ័យដ៏ធ្ងន់ធ្ងររបស់ពួកវាបានឡើយ។

នៅដើមខែ មីនា ឆ្នាំ ១៩៧៤ កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានជំរុញការវាយប្រហារពីគ្រប់ទិសទីរហូតចូលមកដល់ជិតភ្នំពេញ ពីខាងពាយព្យ និរតី ក៏ដូចពីខាងបូព៌ា ឧត្តរ និងអាគ្នេយ៍។ កងទ័ពប្រជាជនបានកម្ទេចទីតាំងឈរជើងជាច្រើន និងកម្លាំងស្រួចសំខាន់ៗរបស់ខ្មាំង។ កងកាំភ្លើងធំរបស់កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានផ្ដោងដាក់ទីតាំងយោធាទាំងអស់ នៅក្នុងក្រុងយ៉ាងខ្លាំងក្លាបំផុត ហើយធ្វើឲ្យកងទ័ពខ្មាំងទទួលការបាត់បង់យ៉ាងដំណំ បាក់ស្មារតី និងរត់ចែកជើងគ្នា។

ក្នុងអំឡុងពេលដែលពួកអាក្បត់ភ័យស្លន់ស្លោនៅជុំវិញ និងក្នុងទីក្រុងភ្នំពេញ កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានកម្ទេចពួកវា នៅផ្លូវជាតិលេខ៤ទៀត នៅខាងកើតក្រុងកំពង់ស្ពឺ ដោយបោសសំអាតហ្វូងកងទ័ពអាយ៉ងលើកំណាត់ផ្លូវ អង្គស្នួល-វល្លិ៍ស ជាពិសេសជុំវិញ និងទីស្នាក់ការរដ្ឋបាលនៃស្រុកព្រែកផ្ដៅ។ ពួកអាក្បត់មិនទាន់បាត់ភ័យស្លន់ស្លោនៅឡើយទេ ដោយនៅលើផ្លូវជាតិលេខបួន នៅខេត្តកំពត

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

ពួកវាត្រូវបានវាយប្រហារ ហើយដែលនៅក្នុងរយៈពេលដ៏ខ្លីបំផុត កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានកម្ទេចប្រព័ន្ធការពាររបស់ពួកវា និងសម្រុកចូលទីក្រុងយ៉ាងរហ័សពីគ្រប់ទិសទី។ អគ្គសេនាធិការកងទ័ពក្បត់ទុច្ចរិតបានទទួលរងការវាយប្រហារ ដោយមិនអាចដឹងមុន និងវង្វេងវង្វាន់ស្មារតីជាថ្មីម្តងទៀត រហូតដល់ពេលដែលស្ថានទូតអាមេរិកនៅទីក្រុងភ្នំពេញបញ្ជូននាយទាហានអាមេរិកមកសមរភូមិ ដើម្បីកាន់បញ្ជាការដោយផ្ទាល់ ពីលើក្បាលពួកបរិវាររបស់ពួកវា។ ខ្មាំងបានដកកម្លាំងវាមួយផ្នែកពីភ្នំពេញដើម្បីបញ្ជូនទៅកំពត។ ប៉ុន្តែ នៅពេល ដែលពួកខ្មាំងខ្វះកម្លាំងនៅភ្នំពេញ កាលពីថ្ងៃទី ១៤ ខែមីនា កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានបើកការវាយលុកលើទីតាំងកោះដាច់ (ខ្សាច់កណ្តាល) និងកោះឧកញ៉ាតី លើទន្លេមេគង្គ ចម្ងាយ៦គម ពីព្រះបរមរាជវាំង (ក្រុងភ្នំពេញ)។ ក្នុងរយៈពេលមួយយប់មួយថ្ងៃ កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានរំដោះកោះទាំងនេះ ហើយកម្ទេចកងវរសេនាតូចរបស់ខ្មាំងបានមួយ និងបានជួយនាំប្រជាជនចំនួន ៥០ ០០០ នាក់ ទៅតំបន់រំដោះ។ ពួកអាក្បត់ លន់ នល់ និង ស្វ័ស្តែន ហ្វៃវណង់ដែស មេខ្លោងនៃបញ្ជាការកងទ័ពក្បត់ក្រុងភ្នំពេញហើបមាត់មិនរួចអំពីបរាជ័យនេះ ពីព្រោះពួកវារកលេសមកបោកប្រាសគេ និងអួតក្អេងក្អាងដូចមុនទៀតលែងបាន។

[ERN00000094]

មួយថ្ងៃបន្ទាប់មក គឺថ្ងៃទី ១៥ ខែមីនា កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានវាយប្រហារជាថ្មីម្តងទៀតយ៉ាងខ្លាំង និងដោយមិនឲ្យខ្មាំងដឹងមុន នៅក្រុងឧដុង្គ។ នៅថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៧៤ កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានរំដោះទឧដុង្គបានទាំងស្រុង។ កងពលខ្មាំងមួយត្រូវបានកម្ទេច ហើយប្រជាជនចំនួន ៣០ ០០០ នាក់ នៃក្រុងនេះ និងតំបន់នៅជុំវិញ បានទៅដល់តំបន់រំដោះ ដោយជោគជ័យ។ ទាល់តែកងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានបំផ្លាញទាំងស្រុង នូវប្រព័ន្ធទីតាំងទ័ព អំណាចរដ្ឋបាលជំរំឃុំឃាំង មជ្ឈមណ្ឌលសន្តិភាព នៅក្រុងឧដុង្គរួចហើយ ទើបពួកអាក្បត់ប្រញ៉ាប់ប្រញ៉ាល់បញ្ជូនកម្លាំងជំនួយ ដើម្បីដណ្តើមយកក្រុងឧដុង្គវិញ។ ប៉ុន្តែ កម្លាំងជំនួយនេះត្រូវបានកម្ទេចយ៉ាងដំណំ និងសម្លាប់ជាច្រើននាក់។

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

ព្រឹត្តិការណ៍លើផ្នែកយោធាទាំងអស់នេះបង្ហាញឲ្យឃើញថាខ្មាំងបាត់ការផ្តួចផ្តើមទាំងអស់ ហើយរត់តាមស្ថានការណ៍ និងទាល់ច្រកបានត្រឹមតែវាយការពារខ្លួនតែប៉ុណ្ណោះ។ ដោយឡែក កងទ័ពប្រជាជនរំដោះជាតិកម្ពុជាវិញកំពុងវាយប្រហារខ្មាំងគ្រប់ទិសទី ទៅតាមផែនការរបស់ខ្លួន និងកម្ទេចកម្លាំងស្រួចយ៉ាងច្រើន នៅលើគ្រប់ទីលានប្រយុទ្ធ។

ដោយសង្ខេប ខ្មាំងស្ពន់ស្ពោដល់កម្រិត និងវង្វេងវង្វាន់ស្មារតីពេញទំហឹង។ កងទ័ពប្រជាជនរំដោះជាតិកម្ពុជានឹងវាយប្រហារវានៅគ្រប់ទិសទី ខ្លាំងជាងនេះទៀត និងធ្វើឲ្យវាទាល់ច្រកក្នុងសភាពស្ពន់ស្ពោជាងនេះទៀតរហូតដល់កម្ទេចពួកអាក្បត់មាតុភូមិបានទាំងអស់។

## ល្បិចថោកទាប និងអំពើខ្មាស់ជនរបស់ចក្រពត្តិអាមេរិក និងបរិវាររបស់វានាទីក្រុងភ្នំពេញ

<u>ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ចេញផ្សាយថ្ងៃទី ៥ ខែ មេសា ឆ្នាំ ១៩៧៤</u>

ពួកចក្រពត្តិអាមេរិកបានប្រើល្បិចថ្មីមួយកាន់តែថោក និងកំសាក ប្រឆាំងនឹងប្រជាជនកម្ពុជា ពីព្រោះតាមរយៈ CIA ពួកវាបានដាក់ឲ្យដំណើរការភ្នាក់ងារផ្សព្វផ្សាយវិទ្យុ ថ្លែងបន្លំថាជាវិទ្យុរបស់រណសិរ្សរួបរួមតំបន់ឥណ្ឌូចិន។ល។ អ្វីដែលធ្វើឲ្យគេចង់ក្អួតជាងនេះទៅទៀតនោះ គឺថាពួកបនក្បត់ លន់ នល់ សិរីមតៈ សឺង ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត ស្វ៊ស្តែន ហ្វៃរណង់ដែស និងវិទ្យុរបស់ពួកវានៅទីក្រុងភ្នំពេញ ពឹងផ្អែកយ៉ាងថោកទាបបំផុតលើវិទ្យុ CIA ដោយមិនខ្មាស់អៀនទាល់តែសោះ។

ចាប់តាំងពីខែ សីហា ឆ្នាំ ១៩៧៣ "ខ្មែរភាវូបនីយកម្ម" នៃសង្គ្រាមនៅកម្ពុជាត្រូវបានវាយប្រជាជន និងកងទ័ពប្រជាជនរំដោះជាតិកម្ពុជាវាយប្រហារយ៉ាងដំណំ និងកាន់តែទ្រុតទ្រោមពីមួយថ្ងៃទៅមួយថ្ងៃ។ លើសពេលណាៗទាំងអស់ ពួកអាចោរក្បត់ លន់ នល់ សិរីមតៈ សឺង ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត ស្វ៊ស្តែន ហ្វៃរណង់ដែស ត្រូវបានរុញច្រានឲ្យធ្លាក់ដុនដាបលើគ្រប់វិស័យ។ ដើម្បីព្យាយាម

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

សង្គ្រោះជីវិតបរិវាររបស់ខ្លួននៅទីក្រុងភ្នំពេញ ចក្រពត្តិអាមេរិក ជាពិសេសរដ្ឋាភិបាលនិចសុនបានបង្កើនការធ្វើអន្តរាគមន៍ និងការឈ្លានពានលើប្រទេសកម្ពុជា ដោយប្រើមធ្យោបាយថោកទាបបំផុត។ ពួកវាបានបញ្ជូលទីប្រឹក្សាយោធាចំនួន ៣៥០០ នាក់ដើម្បីបញ្ជាលើក្បាលពួកអាក្បត់ ក្នុងគ្រប់វិស័យ ជាពិសេសវិស័យយោធា។

[ERN00000095]

តាមរយៈ CIA និងដោយល្បិចដ៏កខ្វក់ និងថោកទាបបំផុត ពួកវាបានបញ្ជូលភ្នាក់ងាររបស់ពួកវាក្នុងអង្គការ "ខ្មែររំដោះ" ក្លែងក្លាយ ដែលសុំចុះចូល។ ពួកវាបានបង្កើតឲ្យមាន "ការសុំចុំចូលរបស់ជនភាសខ្លួន" ខ្លែងក្លាយ។ ពួកវាបំភាន់ភ្នែកក្នុងការឃោសនាបោកប្រាស់ និងមូលបង្កាច់យកអ្វីដែលពួកវាហៅថា "វៀតកុង និងវៀតណាមខាងជើង" ធ្វើជាយុទ្ធជន ក្នុងជួរកងទ័ពខ្មែរក្រហម។

នេះបង្ហាញកាន់តែច្បាស់ថែមទៀតថាពួកវា ទាំងម្ចាស់ ទាំងបរិវារ កាន់តែទាល់ច្រកទៅៗ។ កម្លាំងកងទ័ពប្រជាជន និងប្រជាជនកម្ពុជា ក៏ដូចជាប្រជាជនទាំងឡាយដែលស្រលាញ់យុត្តិធម៌ ក្នុងពិភពលោកកំពុងតែបរិហារ ថ្កោលទោស និងបំបែកបំបាក់ពួកវា។ ការដែលពិភពលោកទាំងមូលកំពុងតែស្តាប់លោកឧបនាយករដ្ឋមន្ត្រី ខៀវ សំផន កំពុងនិយាយអំពីគាត់ និងឃើញគាត់ច្បាស់ ដែលលោកត្រូវបានពួកចក្រពត្តិអាមេរិក និងបរិវាររបស់វា ពួកអាក្បត់បានប្រកាសកុហកថាស្លាប់បាត់ទៅហើយនោះ ជាការទះមួយកំផ្លៀងចំកណ្តាលមាត់ពួកអាកំភូតតែម្តង។

## បញ្ជីទីមួយនៃទីប្រឹក្សាយោធាអាមេរិកនៅទីក្រុងភ្នំពេញ ÷ ភស្តុតាងដែលមិនអាចប្រកែកបាននៃអន្តរាគមណ៍ផ្ទាល់របស់ពួកចក្រពត្តិអាមេរិកក្នុងសង្គ្រាមឈ្លានពាននៅកម្ពុជា

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

<u>ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ចេញផ្សាយថ្ងៃទី ៧ ខែ មេសា ឆ្នាំ ១៩៧៤</u>

ពួកចក្រពត្តិអាមេរិកកំពុងធ្វើអន្តរគមន៍កាន់តែផ្ទាល់ និងកាន់តែជ្រៅទៅៗ ក្នុងសង្គ្រាមឈ្លានពានលើកម្ពុជា។

ចាប់តាំងពីថ្ងៃ ១៨ ខែ មិនា ឆ្នាំ ១៩៧០ ជាកាលបរិច្ឆេទដែលពួកវាបង្កចលនាធ្វើរដ្ឋប្រហារប្រតិកិរិយាផ្តួលរំលំកម្ពុជាឯករាជ្យ សន្តិភាព អព្យាក្រឹត និកសុនបានផ្តល់ជំនួយយ៉ាងសន្ធឹកសន្ធាប់ ក្នុងវិស័យយោធា សេដ្ឋកិច្ច និងនយោបាយ ទៅដល់បរិវាររបស់វានៅទីក្រុងភ្នំពេញ ពួកអាបនក្បត់ លន់ នល់ សិរីមតៈ សឺង ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត ស្វ័ស្តែន ហ្វែរណង់ដែស ដើម្បីឱ្យពួកនេះសម្លាប់ និងផ្តាច់ដង្ហើមការតស៊ូដ៏ត្រឹមត្រូវរបស់ប្រជាជនកម្ពុជា។

ប៉ុន្តែក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ ពួកអាក្បត់នៅទីក្រុងភ្នំពេញទទួលបរាជ័យកាន់តែធ្ងន់ធ្ងរទៅៗ ក្នុងគ្រប់វិស័យ និងងើបក្បាលមិនរួច។ ដើម្បីសង្គ្រោះពួកវា ពួកអាចក្រពត្តិអាមេរិកបានបញ្ជូនទីប្រឹក្សាយោធាជាច្រើន មកប្រទេសកម្ពុជាដើម្បីឱ្យដឹកនាំកងទ័ព និងរដ្ឋការខុសច្បាប់នាទីក្រុងភ្នំពេញ។ សព្វថ្ងៃនេះ ទីប្រឹក្សាយោធាអាមេរិកមានចំនួន ៣ ៥០០ នាក់ ហើយនិកសុនមានគំរោងបង្កើនចំនួន ដល់ ១០ ០០០ នាក់ នៅចុងឆ្នាំនេះ។ ពួកទីប្រឹក្សាយោធាអាមេរិកទាំងអស់នេះ ដែលភាគច្រើនស្លៀកពាក់ជាប្រជាជនស៊ីវិល ធ្វើសកម្មភាពឈ្លានពានក្នុងគ្រប់វិស័យ ជាពិសេសវិស័យយោធា។

យើងបោះពុម្ពផ្សាយខាងក្រោម បញ្ជីដំបូងនៃទីប្រឹក្សាយោធាអាមេរិកាំងដែលសព្វថ្ងៃកំពុងតែដឹកនាំសង្គ្រាមឈ្លានពានរបស់ចក្រពត្តិ អាមេរិកនៅកម្ពុជា៖

[ERN00000096]

| | | |
|---|---|---|
| 1. | Cleland John | ឧត្តមសេនីយទោ |
| 2. | Burnelle Ray | វរសេនីយឯក |
| 3. | Donaldson John | វរសេនីយឯក |

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

| | | |
|---|---|---|
| 4. | Grayeb George | វរសេនីយឯក |
| 5. | Munnelly John | វរសេនីយឯក |
| 6. | Opfer David | វរសេនីយឯក |
| 7. | Turnip Seed Charles | វរសេនីយឯក |
| 8. | Banne William | វរសេនីយទោ |
| 9. | Barnee William | វរសេនីយទោ |
| 10. | Borent Mark | វរសេនីយទោ |
| 11. | Broman Ralph | វរសេនីយទោ |
| 12. | Trampbell James | វរសេនីយទោ |
| 13. | Tronetti Robert | វរសេនីយទោ |
| 14. | Dorant Edwin | វរសេនីយទោ |
| 15. | Edwards Richard | វរសេនីយទោ |
| 16. | Hawkins Richard | វរសេនីយទោ |
| 17. | Hes Ted | វរសេនីយទោ |
| 18. | Holkau Kohn | វរសេនីយទោ |
| 19. | Lundgren Duway Ne | វរសេនីយទោ |
| 20. | Meyer Frederick | វរសេនីយទោ |
| 21. | Newhan Donald | វរសេនីយទោ |
| 22. | Sullivan Roy | វរសេនីយទោ |
| 23. | Whithire Roy | វរសេនីយទោ |
| 24. | Barnei Walter | វរសេនីយទោ |
| 25. | Berry John | មេបញ្ជាការកងវរសេនាធំ |
| 26. | Buller Perry | មេបញ្ជាការកងវរសេនាធំ |
| 27. | Childere Charles | មេបញ្ជាការកងវរសេនាធំ |

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

28. Custer Bert, មេបញ្ជាការកងវរសេនាធំ
29. Dowds James មេបញ្ជាការកងវរសេនាធំ
30. Even Donals មេបញ្ជាការកងវរសេនាធំ
31. Goldesith Nathan មេបញ្ជាការកងវរសេនាធំ
32. Gott Schark Paul មេបញ្ជាការកងវរសេនាធំ
33. Hill Paul មេបញ្ជាការកងវរសេនាធំ
34. Kobg Ronald មេបញ្ជាការកងវរសេនាធំ
35. Lane Charles មេបញ្ជាការកងវរសេនាធំ
36. Lawton George មេបញ្ជាការកងវរសេនាធំ
37. Loban Gary Grant មេបញ្ជាការកងវរសេនាធំ
38. Manges Duff មេបញ្ជាការកងវរសេនាធំ
39. Meeth Harry មេបញ្ជាការកងវរសេនាធំ
40. Menoher Paul មេបញ្ជាការកងវរសេនាធំ
41. Mott William មេបញ្ជាការកងវរសេនាធំ
42. Fannmaller Walter មេបញ្ជាការកងវរសេនាធំ
43. Von Hoene John Paul មេបញ្ជាការកងវរសេនាធំ
44. Washan Billy មេបញ្ជាការកងវរសេនាធំ
45. Stepane Vitch Sava មេបញ្ជាការកងវរសេនាធំ
46. Buch David វរនាវីឯក
47. Bush Vernon វរនាវីឯក
48. Geary Richard វរនាវីឯក
49. Cosgrove Patrich វរសេនីត្រី
50. Dubois Denis វរសេនីត្រី
51. Clark Michael អនុសេនីឯក

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

52. Hamer Robert អនុសេនីឯក

[ERN00000097]

53. Jensen Bruces អនុសេនីឯក
54. Manson Lewis អនុសេនីឯក
55. Verdier Bernard អនុសេនីឯក
56. Caroll George អនុសេនីទោ
57. Macon Macdowell John អនុសេនីទោ

ខាងក្រោមនេះ ជាបញ្ជីឈ្មោះទីប្រឹក្សាឃោឃាក្លែងខ្លួនជាស៊ីវិលដើម្បីបំភាន់មតិសាធារណជន៖

1. Barnhicall Gary
2. Bellefeuilles Gil
3. Bick Paul
4. Blake Thomas
5. Boys Richard
6. Bewere Ronald
7. Brogger Ellen
8. Buchanan Michael
9. Bull Kinlock
10. Burger Albert
11. Butler Cletes
12. Carway Rayford
13. Carney Timethy
14. Carpenter Karl
15. Cartwright Glenn
16. Chamberlain Arthur
17. Cronboy Stephen
18. Cooney Magaret
19. Davis Peter
20. Driscell Joseph
21. Djiewit Maria
22. Ellissabide Pierre
23. Gaetka Annders
24. Ennis Robert
25. Evans Benjamin
26. Evans George

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

27. Faria Joseph
28. Fassett Richard
29. Flahart Michael
30. Frudger Wayne
31. Gemet David
32. Gardner Paul
33. Goodnough Andrey
34. Grant Theodora
35. Granzow Elizabeth
36. Graffin James
37. Grull David
38. Guideche Larry
39. Guidemette Howard
40. Halton Travis
41. Harben William
42. Harper Dana
43. Harick Philip
44. Herlin Arthur
45. Hice Daniel

[ERN 00000098]

46. Hosbrook Thomas
47. Howard Andrew
48. Jacket Loon
49. Jacodson Annarose
50. Jacobson Robert
51. Jameson Donald
52. Johnson Franch
53. Jones Paul
54. Kincaid William
55. Keshe Aliff Bruno
56. Laboube Thomas
57. Leedodd Leenodd
58. Lech John
59. Lech Harry
60. Maocarthy John
61. Mac Coy Jame
62. Mac Kissen Laurech
63. Mikkelson Orry
64. Willington Jeffrey
65. Misewecz Marynalee
66. Maccana Patricia
67. Moreski Donald

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

68. Navratil William
69. Nelson Richard
70. Newman Irwin
71. Wifadzw Michael
72. Odanil Larry
73. Elson Stuart
74. Parrish Earl
75. Priluker Charlotte
76. Prior Greogr
77. Pulh Harold
78. Ramsy Jlaiam
79. Rasberry Donald
80. Reed Bernard
81. Radwans Charles
82. Riley Wallace
83. Rose Joe
84. Sanabria Erique
85. Satcher Stwlvester
86. Strhwam Theodore
87. Shopard Michael
88. Sirok Manirns
89. Simpson Greald
90. Smith Arthur
91. Smith Leas Ruth
92. Soergrel Donald
93. Sohlin Donelly
94. Spiney Norman
95. Stallivier Norman
96. Stuart Ongo Michaul

[ERN 00000099]

97. Sturgron Grogr
98. Svoboda Josef
99. Svoboda Veray
100. Taubs Serge
101. Tague Bobby
102. Thacher Richard
103. Thowson Raymond
104. Towsend Jacekarne
105. Tripp Richard
106. Vahai Ric
107. Warren Arthur
108. Weman Miles

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]

109. Weden Charles
110. Waleh Iron

# ទីតាំងឈរជើងការពារក្រុងពោធិ៍សាត់មួយកន្លែងត្រូវបានកម្ទេច

<u>ទីភ្នាក់ងារព័ត៌មានកម្ពុជាចេញផ្សាយថ្ងៃទី ៧ ខែ មេសា ឆ្នាំ ១៩៧៤</u>

នៅវេលាយប់នាថ្ងៃទី ២៧ ខែ មីនា កន្លងទៅនេះ កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានបើកយុទ្ធនាការវាយប្រហារយ៉ាងខ្លាំងក្លាបំផុតទៅលើទីតាំងរលប់ស្ថិតនៅលើខ្សែត្រៀម និងមានចម្ងាយ៦គម នៅផ្នែកនិរតី នៃក្រុងពោធិ៍សាត់។

ក្រោយពីវាយប្រហារយ៉ាងស្វិតស្វាញអស់រយៈពេលពីរម៉ោង កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានកម្ទេចទីតាំងនេះទាំងស្រុង ព្រមទាំងប្រព័ន្ធ “ស្វ័យការពារ” ដែលនៅជុំវិញទីតាំងនេះ។ កងទ័ពប្រជាជនរំដោះ ជាតិកម្ពុជាបានសម្លាប់ពួកទាហានស៊ីឈ្នួលចំនួន១៥០នាក់ បង្ករបួសជាច្រើននាក់ និងរឹបអូសបាន អាវុធគ្រប់ធុនចំនួន៥៥ដើម ដែលក្នុងនោះ មានកាំភ្លើលត្បាល់ធុន ៨០មម មួយដើម ៦០មម មួយដើម កាំភ្លើងយន្តធុនកណ្ដាលបីដើម (១៥ AR.១៥) កាប៉ីន ២៨ ដើម ឧបករណ៍បញ្ជូនព័ត៌មានមួយគ្រឿង គ្រាប់កាំភ្លើងត្បាល់ និងគ្រាប់កាំភ្លើងធុនស្រាលជិតមួយតោន និងសម្ភារៈសឹកផ្សេងៗទៀតប្រហែលបីតោន។ ប្រជាជនជាង១០០គ្រួសារដែលខ្មាំងបានឃុំខ្លួនសម្រាប់ធ្វើជាខែលការពារ ត្រូវបានរំដោះ។

Original FR: S 00000086-00000099
Translated: [00000088];[00000089]; [00000090], [00000091]; [00000092]; [00000093]; [00000094]; [00000095]; [00000096]; [00000097]; [00000098]; [00000099]